## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ១១៥

ចុះថ្ងៃទី១៧-០១-២០២២

**សាលដីកា**

លេខ ៧២ "ក្រ IV ទល"

ចុះថ្ងៃទី០៦-០៩-២០២២

## គាននាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមនស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦-៧-២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលសវនាការសាលាឧទ្ធរណ៍នាថ្ងៃទីដប់មួយ ខែសីហា ឆ្នាំពីរពាន់ម្ភៃពីរ ដោយមានសមាសភាពដូចខាងក្រោម ៖

### **ក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា

លោកជំទាវ [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

### **តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

### **ក្រឡាបញ្ជី**

កញ្ញា [redacted] ជាក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១១៥ ចុះថ្ងៃទី ១៧-០១-២០២២ ដែលមាន៖

-ជនជាប់ចោទឈ្មោះ [redacted] ជីវ៉ា ភេទប្រុស អាយុ ២៥ឆ្នាំ កើតឆ្នាំ១៩៩៥ ជនជាតិខ្មែរ មុខរបរបើកឡានដឹកដំឡូង ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តព្រៃវែង ទីលំនៅមុនពេលឃាត់ខ្លួន [redacted] ខេត្តប៉ៃលិន ប្រពន្ធឈ្មោះ [redacted] (លែងលះ) ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ជានីតិជន ទោសពីមុនគ្មាន។(ប្តឹងឧទ្ធរណ៍)

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ: ១២៦៤៦ "ទ" ដ.យ.ដ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ នៅមណ្ឌលអប់រំកែប្រែទី១។

-មានមេធាវី [redacted] សុវណ្ណដារ៉ា និងមេធាវី [redacted] ទេសកញ្ញៈនា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

<u>ជាប់ចោទពីបទ៖</u> **រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ** ប្រព្រឹត្តនៅភូមិថ្មីក្រៅ ឃុំរះជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង កាលពីអំឡុងខែឧសភា ឆ្នាំ២០១២ និងនៅចំណុចភូមិបឹងព្រលិត សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ។





Scanned with CamScanner

-ជនរងគ្រោះឈ្មោះ [redacted] ម៉ូលីកា ភេទស្រី អាយុ ១៤ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស ទីលំនៅបច្ចុប្បន្ន [redacted] រាជធានីភ្នំពេញ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វណ្ណៈ ភេទស្រី អាយុ ៣៤ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមេផ្ទះទីលំនៅ [redacted] រាជធានីភ្នំពេញ។

## ឯរឿងហេតុមានដូចតទៅ

នៅក្នុងអំឡុងឆ្នាំ២០១២ ឈ្មោះ [redacted] វណ្ណៈ បានយកកូនស្រីឈ្មោះ [redacted] ម៉ូលីកា ភេទស្រី អាយុ០៨ឆ្នាំ និងកូនប្រុសឈ្មោះ [redacted] លីមហេង ភេទប្រុស អាយុ ០៥ឆ្នាំ ទៅរស់នៅជាមួយលោកយាយឈ្មោះ [redacted] តាំងអួន នៅភូមិថ្មីក្រៅ ឃុំរះជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង។ លុះមកដល់ខែឧសភា ឆ្នាំ២០១២ ជនសង្ស័យឈ្មោះ [redacted] ធីរ៉ា ភេទប្រុស ដែលរស់នៅជាមួយយាយដែរនោះ បានចាប់រំលោភសេពសន្ថវៈ លើឈ្មោះ [redacted] ម៉ូលីកា បានសម្រេច ៤ទៅ ៥ដង និងបានគម្រាមជនរងគ្រោះមិនអោយយករឿងនេះទៅប្រាប់យាយ។ លុះដល់ឆ្នាំ២០១៥ ខណៈពេលដែលយាយឈ្មោះ [redacted] តាំងអួន មិននៅផ្ទះស្រាប់តែឈ្មោះ [redacted] ធីរ៉ា បានធ្វើសកម្មភាពរំលោភលើជនរងគ្រោះឈ្មោះ [redacted] ម៉ូលីកា បានសម្រេច ២ដងទៀត ហើយនៅក្នុងឆ្នាំ២០១៥ ដដែលនោះយាយឈ្មោះ [redacted] តាំងអួន ក៏បាននាំចៅៗខាងលើមករស់នៅភ្នំពេញ នៅភូមិបឹងព្រលិត សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។ លុះមកដល់ឆ្នាំ២០២០ ឈ្មោះ [redacted] វណ្ណៈ ជាម្តាយ ត្រឡប់មកពីធ្វើការនៅប្រទេសថៃវិញ និងបានមករស់នៅជាមួយកូនៗវិញ នៅរាជធានីភ្នំពេញ ខណៈនោះកូនស្រីឈ្មោះ [redacted] ម៉ូលីកា ក៏បានប្រាប់ម្តាយអំពីរឿងហេតុដែលបានកើតឡើងខាងលើ បន្ទាប់មកម្តាយឈ្មោះ [redacted] វណ្ណៈ ក៏បានដាក់ពាក្យបណ្តឹងទៅសមត្ថកិច្ច ហើយនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ សមត្ថកិច្ចក៏ឃាត់ខ្លួនឈ្មោះ [redacted] ធីរ៉ា បានតែម្តងទៅខេត្តប៉ៃលិន។

-បានឃើញ ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ធីរ៉ា នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា ខ្លួនមានស្រុកកំណើតនៅភូមិថ្មីក្រៅ ឃុំរក្សជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែងមានឪពុកឈ្មោះ [redacted] ឈុន អាយុ ៥៤ឆ្នាំ(រស់) ម្តាយឈ្មោះ [redacted] សុម៉ាលី អាយុ ៣៨ឆ្នាំ(រ) ហើយរូបខ្លួនមានបងប្អូនបង្កើតចំនួន ០៣នាក់ ហើយរូបខ្លួនគឺជាកូនទី៣។ រូបខ្លួនត្រូវបានម្តាយឪពុកយករូបខ្លួនឱ្យទៅរស់នៅជាមួយលោកយាយនៅក្នុងភូមិថ្មីក្រៅ ឃុំរក្សជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង ហើយឪពុកម្តាយខ្លួនរួមទាំងបងៗបានមករកស៊ីនៅភ្នំពេញនៅម៉ុំទឹកថ្លា ក្នុងខណ្ឌសែនសុខ ចំណែករូបខ្លួនរៀនចប់នៅត្រឹមថ្នាក់ទី៦ តែប៉ុណ្ណោះនៅពេលរស់នៅជាមួយលោកយាយខ្លួនមានអាយុ ១៥ឆ្នាំ។ នៅឆ្នាំ២០១២ ម្តាយមីងខ្លួនឈ្មោះ [redacted] វណ្ណៈ ដែលត្រូវជាប្អូនស្រីឪពុកខ្លួនបានយកកូនស្រីរបស់គាត់ឈ្មោះ [redacted] ម៉ូលីកា អាយុ ០៨ឆ្នាំ ឱ្យមករស់នៅជាមួយលោកយាយដូចខ្លួនដែរ ដោយម្តាយគាត់ដែលត្រូវជាម្តាយមីងខ្លួននោះ គាត់បានចេញទៅរកស៊ីនៅប្រទេសថៃ ហើយពេលដែលបងប្អូនជីដូនមួយខ្លួនឈ្មោះ [redacted] ម៉ូលីកា រស់នៅជាមួយខ្លួននៅក្នុងផ្ទះយាយនៅឯខេត្តព្រៃវែងដោយនៅវេលាម៉ោងប្រហែល១២ និង០០នាទីថ្ងៃត្រង់ ក្នុងអំឡុងឆ្នាំ២០១២ ពេលដែលលោកយាយអត់នៅផ្ទះ ខ្លួនបានលួងលោមចាប់រំលោភប្អូនជីដូនមួយខ្លួនឈ្មោះ [redacted] ម៉ូលីកា នៅលើគ្រែ ដោយមិនបានពាក់ស្រោមទេ ខ្លួនបានយកប្រដាប់ភេទទៅដាក់ចូលប្រដាប់ភេទនាង ហើយញុលចុះញុលឡើង តែអត់ចេញទឹកទេ ហើយសកម្មភាពខាងលើ ខ្លួនបានធ្វើចំពោះនាងបានសម្រេចចំនួន០៣ ទៅ ០៤ដង ហើយក៏មិនចេញទឹកទាំងអស់។ ក្រោយមកក្នុងឆ្នាំ២០១២ លោកយាយបានប្តូរផ្ទះចេញពីខេត្តព្រៃវែងមករស់នៅក្នុងភូមិបឹងព្រលិត សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ចំណែករូបខ្លួនរួម និងប្អូនជីដូនមួយខ្លួនឈ្មោះ [redacted] ម៉ូលីកា ក៏មកនៅជាមួយលោកយាយដែរ ហើយពេលខ្លួនរស់នៅជាមួយលោកយាយ ខ្លួនបានចាប់រំលោភប្អូនជីដូនមួយខ្លួន



Scanned with CamScanner

បានសម្រេចចំនួន០១ដងទៀតគឺនៅក្នុងផ្ទះលោកយាយនៅពេលថ្ងៃម៉ោងប្រហែល០១រសៀល ហើយពេលខ្លួនចាប់រំលោភនាងគឺ ខ្លួនធ្វើសកម្មភាពដាក់ប្រដាប់ភេទខ្លួនចូលក្នុងប្រដាប់ភេទនាង ហើយញុលចុះញុលឡើង តែមិនបានចេញទឹកទេ។ ក្រោយមកទៀតនៅឆ្នាំ២០១៣ ខ្លួនបានចេញទៅធ្វើការនៅខេត្តប៉ៃលិន ដោយធ្វើការជាកម្មករដំឡូងជាមួយពូ ហើយខ្លួនធ្វើការនៅទីនោះអស់រយៈពេលប្រហែលមួយឆ្នាំហើយ ដោយគេឲ្យខ្លួនឡើងបើកឡានចូលដំឡូង និងដឹកដំឡូង លុះក្រោយមកទៀតនៅក្នុងឆ្នាំ២០១៦ ខ្លួនបានរៀបការជាមួយនារីម្នាក់ឈ្មោះ [redacted] ចន្ធី នៅខេត្តប៉ៃលិន ក្នុងស្រុកសាលាក្រៅ ដោយខ្លួននៅជាមួយគ្នាបានរយៈពេល ០៣ឆ្នាំ និងមានកូនជាមួយគ្នាបានកូនស្រីម្នាក់ អាយុ ០៣ឆ្នាំ តែក្រោយមកពួកខ្លួនទាំងពីរនាក់ បានលែងលះគ្នាដោយសារការរស់នៅមិនចុះសម្រុង។ ជាក់ស្តែងនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២០ ម៉ោង២០ និង០០នាទីយប់ ស្រាប់តែមានសមត្ថកិច្ចចុះទៅនាំខ្លួននៅកន្លែងការដ្ឋានដំឡូង ដើម្បីយកមកធ្វើការសាកសួរអំពីរឿងខ្លួនចាប់រំលោភសេពសន្ថវៈលើប្អូនស្រីជីដូនមួយខ្លួនតាំងពីឆ្នាំ២០១២ មកម្លេះ។

-**បានឃើញ** ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ជីវ៉ា** នៅដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរប្រហាក់ប្រហែលគ្នាថា ខ្លួនសូមទទួលស្គាល់ចម្លើយដែលបានឆ្លើយនៅសមត្ថកិច្ច និងនៅអយ្យការទុកជាបានការដដែល ដោយខ្លួនសូមបដិសេធថា ខ្លួនមិនបានគំរាមសម្លាប់ទេ។ កាលពីអំឡុងឆ្នាំ២០១១ មីងរបស់ខ្លួនឈ្មោះ [redacted] វណ្ណៈ បានយកកូនគាត់ចំនួន ០២នាក់ឈ្មោះ [redacted] **ម៉ូលីកា** និងឈ្មោះ [redacted] **លឹមហេង** មកផ្ញើនឹងយាយខ្លួននៅខេត្តព្រៃវែង។ ដោយអំឡុងឆ្នាំ២០១១ នោះ នៅថ្ងៃខែមិនចាំ នៅពេលដែលយាយខ្លួនមិននៅផ្ទះខ្លួនបានចាប់រំលោភប្អូនស្រីជីដូនមួយខ្លួនឈ្មោះ [redacted] **ម៉ូលីកា** ភេទស្រី អាយុ ០៨ឆ្នាំ បានសម្រេចចំនួន ០៣ដង ដោយពុំមានប្រើស្រោមអនាម័យឡើយ។ ក្រោយពេលរំលោភរួចខ្លួនបានគំរាមមិនអោយឈ្មោះ [redacted] **ម៉ូលីកា** ប្រាប់អ្នកណាទេ ហើយកាលនោះខ្លួនមានអាយុ ១៥ឆ្នាំ។ លុះដល់ឆ្នាំ២០១២ យាយខ្លួនបានមករស់នៅភ្នំពេញ ហើយខ្លួន និងឈ្មោះ [redacted] **ម៉ូលីកា** និងប្អូនប្រុសគេឈ្មោះ **ហេង** ក៏បានមករស់នៅភ្នំពេញជាមួយយាយដែរ។ ហើយរយៈពេលដែលមករស់នៅភ្នំពេញ នៅពេលដែលយាយខ្លួនមិននៅខ្លួនបានចាប់រំលោភប្អូនស្រីខ្លួនឈ្មោះ [redacted] **ម៉ូលីកា** បានចំនួន ០១លើកទៀត។ លុះដល់ឆ្នាំ២០១៣ ខ្លួនបានចាកចេញពីភ្នំពេញ ទៅរស់នៅធ្វើការនៅខេត្តប៉ៃលិន រហូតឈានដល់ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ សមត្ថកិច្ចបានមកឃាត់ខ្លួនខ្លួនបន្ទាប់ពីទទួលបាននូវពាក្យបណ្តឹងរបស់ម្តាយឈ្មោះ [redacted] **ម៉ូលីកា** បានប្តឹងខ្លួនថា ចាប់រំលោភសេពសន្ថវៈលើកូនស្រីគាត់។ កាលពីអំឡុងឆ្នាំ២០១១ នៅខេត្តព្រៃវែង ក្រោយពេលរំលោភរួចខ្លួនបានគំរាមមិនអោយឈ្មោះ [redacted] **ម៉ូលីកា** ប្រាប់អ្នកណាទេ ហើយកាលនោះខ្លួនមានអាយុ ១៥ឆ្នាំ។ លុះដល់ឆ្នាំ២០១២ យាយខ្លួនបានមករស់នៅភ្នំពេញ ហើយខ្លួន និងឈ្មោះ [redacted] **ម៉ូលីកា** និងប្អូនប្រុសគេឈ្មោះ **ហេង** ក៏បានមករស់នៅភ្នំពេញជាមួយយាយដែរ។ ហើយរយៈពេលដែលមករស់នៅភ្នំពេញនៅពេលដែលយាយខ្លួនមិននៅខ្លួនបានចាប់រំលោភប្អូនស្រីខ្លួនឈ្មោះ [redacted] **ម៉ូលីកា** បានចំនួន ០១លើកទៀត។ លុះដល់ឆ្នាំ២០១៣ខ្លួនបានចាកចេញពីភ្នំពេញ ទៅរស់នៅធ្វើការនៅខេត្តប៉ៃលិនរហូតដល់ពេលបច្ចុប្បន្ន។

-**បានឃើញ** ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ជីវ៉ា** នាពេលសវនាការសាលាដំបូងថា កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ ខ្លួនពិតជាបានប្រព្រឹត្តកំហុសលើប្អូនជីដូនមួយឈ្មោះ [redacted] **ម៉ូលីកា** មែន។ ខ្លួនបានប៉ះពាល់លើឈ្មោះ [redacted] **ម៉ូលីកា** ចំនួន ៤លើក លើកទី១ នៅពេលថ្ងៃ ដោយពេលនោះនៅផ្ទះមានតា និងប្អូនជីដូនមួយ ផ្ទះលើមួយជាន់មានឡៅតឿលើ លើកទីពីរ នៅពេលថ្ងៃដែរចំនួន បីដង។ ពេលខ្លួនប៉ះពាល់គាត់ហើយពុំមានកើតអីនោះទេ ហើយក៏ពុំបានគំរាមកំហែងលើក្មេងដែរ។ ម្តាយរបស់គាត់ទើបដឹងនៅក្នុងឆ្នាំ២០២០ នេះទេ ពេលគាត់ដឹងថា កូនគាត់មានរោគស្ត្រី។ ខ្លួនពុំបានរួមភេទជាមួយក្មេងទេ។ នៅពេល



Scanned with CamScanner

នោះខ្លួនមានអាយុ ១៥ឆ្នាំ ចំណែកក្មេងស្រីមានអាយុ ៧ឆ្នាំ ពេលនោះខ្លួនបានទ្រោបពីលើនាងតែមិនបានដាក់ប្រដាប់ភេទរបស់ខ្លួនចូលទៅក្នុងប្រដាប់ភេទក្មេងទេ។ ខ្លួនបានដោះអាវស្រាតខោរបស់ក្មេង និងបានក្រាបពីលើ ដោយបានយកប្រដាប់ភេទរបស់ខ្លួនញុលៗលើក្បាលពោះរបស់ក្មេង ដោយសារនៅពេលនោះខ្លួននៅក្មេងពុំដឹង ហើយពេលនោះខ្លួនពុំបានមើលរឿងអាសអាភាសនោះទេ និងមិនដឹងថា មានអារម្មណ៍បែបណាទេ ហើយការប្រព្រឹត្តរបស់ខ្លួនរាល់ដងពុំមានចេញទឹកកាមនោះទេ។ យាយរបស់ខ្លួនបានផ្លាស់មករាជធានីភ្នំពេញក្នុងឆ្នាំ២០១២ ខ្លួនបានធ្វើសកម្មភាពបែបនេះលើក្មេងស្រីបានម្តង។ ខ្លួនបានជាប់ពន្ធនាគាររយៈពេល ៩ខែមកហើយ និងមានការសោកស្តាយចំពោះសកម្មភាពរបស់ខ្លួនដែលបានប្រព្រឹត្ត និងចង់កែប្រែកំហុស។

-បានឃើញ ចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ម៉ូលីកា នាពេលសវនាការសាលាដំបូងថា កាលពីអំឡុងឆ្នាំ២០១១ ម៉ាក់របស់ខ្លួនទៅថៃហើយបានយកខ្លួនទៅផ្ញើនៅជាមួយយាយ ពេលនោះខ្លួនមានអាយុ ៧ឆ្នាំ បានចូលរៀនហើយ ចំណែកប្អូនរបស់ខ្លួនមិនទាន់ចូលរៀនទេ។ នៅជាមួយយាយតាមានប្រុសៗតែពីរនាក់ទេ។ ឈ្មោះ [redacted] ធីរ៉ា ធ្វើសកម្មភាពរំលោភខ្លួន ៥លើក មានមួយលើនៅភ្នំពេញ តែពុំចូលទេ។ ពេលនោះខ្លួនពាក់រ៉ូប ដោយពេលនោះខ្លួនពុំបានប្រាប់អ្នកណាទេ ព្រោះគាត់បានគំរាមខ្លួន ហើយខ្លួនក៏មិនបានដឹងថា គាត់រំលោភដែរ។ ពេលនោះខ្លួនពាក់រ៉ូប ដោយពេលនោះគាត់បានយកប្រដាប់ភេទរបស់គាត់ដាក់ចូលក្នុងប្រដាប់ភេទរបស់ខ្លួន តែមិនដឹងថា រយៈពេលប៉ុន្មាននាទីនោះទេ ពេលនោះក៏មានការឈឺចាប់ និងមានឈាមនៅប្រដាប់ភេទតែមិនហ៊ានប្រាប់យាយទេ ព្រោះឈ្មោះ [redacted] ធីរ៉ា គាត់គំរាម។ ក្នុងឆ្នាំ២០១៣ ខ្លួនមករស់នៅជាមួយម៉ាក់វិញ មូលហេតុដែលម៉ាក់ដឹងដោយសារខ្លួនមានរោគស្ត្រី ទើបប្រាប់ម៉ាក់នៅក្នុងខែកញ្ញា ឆ្នាំ២០២០ ហើយម៉ាក់ក៏បានជូនទៅពេទ្យ។ ខ្លួនមករដូវនៅក្នុងឆ្នាំ២០១៧ ចំណែកការធ្លាក់សតី តាំងពីឆ្នាំ២០១៤។ នៅពេលគាត់ធ្វើសកម្មភាពរំលោភខ្លួន យាយមិននៅផ្ទះទេ ចំណែកតាគាត់ដេកឈឺនៅផ្ទះ។ តាំងពីឆ្នាំ២០១៤ មកមិនដែលមានអ្នកណាប៉ះពាល់ខ្លួនរបស់ខ្លួនទៀតទេ។

-បានឃើញ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វណ្ណៈ នាពេលសវនាការសាលាដំបូងថា ខ្លួនផ្ញើកូនជាមួយយាយក្នុងឆ្នាំ២០១២ និងយកកូនមកនៅជាមួយខ្លួនវិញក្នុងឆ្នាំ២០១៣ ខ្លួនបោកខោក្នុងឲ្យកូនស្រីឈ្មោះ [redacted] ម៉ូលីកា ឃើញខោក្នុងរបស់កូនប្លែកទើបសួរនាំគាត់ និងបានយកគាត់ទៅពិនិត្យនៅពេទ្យ។ ខ្លួនទើបដឹងក្នុងឆ្នាំ២០២០ នេះទេ មូលហេតុដែលខ្លួនទើបដឹងដោយសារពីមុនខ្លួនមិនបានបោកខោអាវកូនទេ ទើបតែបោកខោអាវឲ្យកូនឃើញខោក្នុងរបស់កូនមានក្លិនស្អុយ និងធ្លាក់ស។ ខ្លួនយកប្តីក្រោយឆ្នាំ២០១៦ និងមានកូនជាមួយគ្នា ២នាក់បន្ថែមទៀត ឪពុកចុងមិនដែលមានបញ្ហាជាមួយអ្នកផ្សេង ឬធ្វើអ្វីកូនទេ។

រឿងក្តីនេះ **សាលាដំបូងរាជធានីភ្នំពេញ** បានសម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ៩៣៥ "ក្រ₂ឈ" ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ផ្តន្ទាទោសឈ្មោះ [redacted] ធីរ៉ា ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិគ្រប់គ្រាន់) ដាក់ពន្ធនាគារកំណត់ ៧(ប្រាំពីរ)ឆ្នាំ គិតពីថ្ងៃបានឃុំខ្លួនបណ្តោះអាសន្នតទៅ ពីបទ រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ប្រព្រឹត្តនៅភូមិថ្មីក្រៅ ឃុំរះជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង កាលពីអំឡុងខែឧសភា ឆ្នាំ២០១២ និងនៅចំណុចភូមិបឹងព្រលិត សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

២.បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ធីវ៉ា សងសំណងជម្ងឺចិត្តចំនួន២០,០០០,០០០(ម្ភៃលាន)រៀល ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វណ្ណៈ។

៣.ប្រគល់ឲ្យម្ចាស់ដើមវិញ៖ ទូរស័ព្ទដៃម៉ាក OPPO ពណ៌ខ្មៅ ចំនួន ០១(មួយ)គ្រឿង។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ និងបន្តសវនាការនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ ឆន ធីវ៉ា និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វណ្ណៈ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-**បានឃើញ** សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ១០៩៦ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ធីវ៉ា សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ៩៣៥ "ក្រ₂ឈ" ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ ត្រង់ចំណុចវិនិច្ឆ័យសេចក្តីទាំងមូលនៃសាលក្រម។

-បានឃើញ របាយការណ៍រឿង ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ភ្នំពេញ។

-បានឃើញ សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២ របស់មហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

## នាពេលសវនាការ

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វណ្ណៈ (អវត្តមាន)

-ជនរងគ្រោះឈ្មោះ [redacted] ប៉ូលីកា ភេទស្រី អាយុ១៤ឆ្នាំ (អវត្តមាន)

## ប្រធានក្រុមប្រឹក្សាអានរបាយការណ៍រឿង

-ជនជាប់ចោទឈ្មោះ [redacted] ធីវ៉ា ឆ្លើយថា មូលហេតុប្តឹងឧទ្ធរណ៍ដោយសារក្នុងអង្គហេតុនៃរឿងមានពិតខ្លះ និងមិនពិតខ្លះ។ កាលកើតហេតុនោះគឺ នៅឆ្នាំ២០១២ បច្ចុប្បន្ននេះខ្លួនអាយុ ២៦ឆ្នាំ។ ជនរងគ្រោះត្រូវជាបងប្អូនជីដូនមួយខ្លួន កាលកើតហេតុនោះ ខ្លួនមិនសូវចាំទេ ជនរងគ្រោះអាយុប្រហែលជា ៨ឆ្នាំ។ ខ្លួនបានប្រព្រឹត្ត ៤ដងទៅលើជនរងគ្រោះ។ ពេលខ្លួនប្រព្រឹត្តនោះខ្លួនអាយុប្រហែលជា ១៥ទៅ ១៦ឆ្នាំ។ ឆ្នាំ២០១៣ ខ្លួនទៅនៅប៉ៃលិន ហើយឆ្នាំ២០១៥ ខ្លួនអត់បានប្រព្រឹត្តទេ ខ្លួនបានប្រព្រឹត្តតែអំឡុងឆ្នាំ២០១១ និង២០១២ទេ។ ខ្លួនទៅធ្វើការនៅទីនោះ។ ពេលនៅតុលាការសាលាដំបូងគេបន្ថែមអង្គហេតុឆ្នាំ២០១៥ចូលទៀត។ យាយខ្លួនគាត់ប្តូរពីផ្ទះនៅខេត្តព្រៃវែង មករស់នៅបឹងព្រលិតនៅចុងឆ្នាំ២០១១។ ពេលប្រព្រឹត្តនោះខ្លួននៅជាមួយបងប្អូនជីដូនមួយទាំងអស់ ៣នាក់ ហើយប្អូនគាត់ម្នាក់បានចេញទៅក្រៅ ខ្លួនក៏បានយកភួយទៅគ្របលើគាត់ ហើយខ្លួនបានរំលោភគាត់ពិតមែន តែអត់បានបង្ខិតបង្ខំគាត់ទេ។ ពេលនោះខ្លួននៅក្មេង ខ្លួនក៏បបួលគាត់ ខ្លួនបានថើបគាត់ បានដោះខោអាវគាត់ចេញអស់ ហើយបានដាក់ប្រដាប់ភេទខ្លួននៅពីលើគាត់ អត់មានដាក់ចូលទេ។ អារម្មណ៍ពេលនោះខ្លួនចាំខ្លះអត់ខ្លះ។ ខ្លួនដឹងថា ខ្លួនធ្វើខុស។ ពេលប្រព្រឹត្តបទល្មើសនោះគឺ ពេលថ្ងៃ។ ពេលនោះអត់បានមើលវីដេអូអ្វីទេ។ ខ្លួនអត់ដែលឃើញ រូបភាពបែបនោះទេ។ អំឡុងពេលប្រព្រឹត្ត ១នាទីទៅ ១នាទីកន្លះ។ នៅក្នុងអំឡុងឆ្នាំ២០១២ នោះខ្លួនប្រព្រឹត្ត ១ទៅ ២ដង ក្រោយប្រព្រឹត្តខ្លួនមានការស្តាយក្រោយ។ ខ្លួនឈប់ប្រព្រឹត្តហើយ។ ពីមុនមកខ្លួនអត់បានស្រលាញ់គ្នាមានស្នេហាអ្វីទេ។ ខ្លួនបាននិយាយជាមួយគាត់រឿងរួមភេទតែអត់បានបង្ខិតបង្ខំជនរងគ្រោះទេ។ សំណូមពរខ្លួនសុំបន្ធូរបន្ថយទោស។

-ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ូលីកា ដែលបានបំភ្លឺថា កាលពីអំឡុងឆ្នាំ ២០១១ ម៉ាក់របស់ខ្លួនទៅថៃហើយបានយកខ្លួនទៅផ្ញើនៅជាមួយយាយ ពេលនោះខ្លួនមានអាយុ៧ឆ្នាំ បានចូលរៀនហើយ ចំណែកប្អូនរបស់ខ្លួនមិនទាន់ចូលរៀនទេ។ នៅជាមួយយាយតាមានប្រុសៗតែពីរនាក់ទេ។ ឈ្មោះ [redacted] ដីវ៉ា ធ្វើសកម្មភាពរំលោភខ្លួន ៥លើក មានមួយលើនៅភ្នំពេញ តែពុំចូលទេ។ ពេលនោះខ្លួនពាក់រ៉ូប ដោយពេលនោះខ្លួនពុំបានប្រាប់អ្នកណាទេ ព្រោះគាត់បានគំរាមខ្លួន ហើយខ្លួនក៏មិនបានដឹងថា គាត់រំលោភដែរ។ ពេលនោះខ្លួនពាក់រ៉ូប ដោយពេលនោះគាត់បានយកប្រដាប់ភេទរបស់គាត់ដាក់ចូលក្នុងប្រដាប់ភេទរបស់ខ្លួន តែមិនដឹងថា រយៈពេលប៉ុន្មាននាទីនោះទេ ពេលនោះក៏មានការឈឺ ចាប់ និងមានឈាមនៅប្រដាប់ភេទតែមិនហ៊ានប្រាប់យាយទេ ព្រោះឈ្មោះ [redacted] ដីវ៉ា គាត់គំរាម។ ក្នុងឆ្នាំ២០១៣ ខ្លួនមករស់នៅជាមួយម៉ាក់វិញ មូលហេតុដែលម៉ាក់ដឹងដោយសារខ្លួនមានរោគស្ត្រី ទើបប្រាប់ម៉ាក់នៅក្នុងខែកញ្ញា ឆ្នាំ២០២០ ហើយម៉ាក់ក៏បានជូនទៅពេទ្យ។ ខ្លួនមករដូវនៅក្នុងឆ្នាំ២០១៧ ចំណែកការធ្លាក់សតី តាំងពីឆ្នាំ ២០១៤។ នៅពេលគាត់ធ្វើសកម្មភាពរំលោភខ្លួន យាយមិននៅផ្ទះទេ ចំណែកតាគាត់ដេកឈឺនៅផ្ទះ។ តាំងពីឆ្នាំ២០១៤ មកមិនដែលមានអ្នកណាប៉ះពាល់ខ្លួនរបស់ខ្លួនទៀតទេ។

**-តំណាងអយ្យការស្នើសុំអោយអានលិខិតកោសល្យវិច័យ។**

-ប្រធានក្រុមប្រឹក្សាអានខ្លឹមសារមាននៅក្នុងលិខិតកោសល្យវិច័យ។

**-តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញធ្វើសេចក្តីសន្និដ្ឋានថា៖** ពាក់ព័ន្ធនៅក្នុងរឿងនេះ ជនជាប់ចោទគាត់បានសារភាពថា បានប្រព្រឹត្តអំពើរួមភេទ ក៏ប៉ុន្តែគាត់អត់បានដាក់ប្រដាប់ភេទបញ្ចូលទៅក្នុងប្រដាប់ភេទជនរងគ្រោះទេ។ តាមលទ្ធផលកោសល្យវិច័យ គឺអត់មានដាច់សន្ទះព្រហ្មចារីយទេ។ ប៉ុន្តែមានភាពឆកនៅលើនោះ ដូចនេះបើជាការដាច់គឺ ពិតជាបានប្រព្រឹត្តសម្រេច។ ហើយចម្លើយរបស់ជនជាប់ចោទបានឆ្លើយថា គ្រាន់តែដាក់នៅពីលើទេ នេះជាចំណុចមួយសូមក្រុមប្រឹក្សាពិនិត្យ និងពិចារណា។ ហើយអំឡុងពេលដែលគាត់ប្រព្រឹត្តនោះគឺគាត់នៅក្មេងគាត់មិនទាន់មានការយល់ដឹងចំពោះរឿងនឹងឡើយ។ សូមក្រុមប្រឹក្សាពិនិត្យឡើងវិញទាក់ទងនឹងបទចោទប្រកាន់ ជាពិសេសចំពោះភស្តុតាងដាក់បន្ទុកគាត់ សុំប្តូរមកជាបទ ប្រទូសកេរខ្មាសវិញ ជាពិសេសពាក់ព័ន្ធនឹងអង្គហេតុ គឺកើតឡើងឆ្នាំ២០១២ ហើយការដាក់បណ្តឹងប្តឹងនៅឆ្នាំ២០២០។ បើចំពោះអង្គហេតុប្រទូសកេរខ្មាសវិញ គឺជាបទមជ្ឈិម ការប្រព្រឹត្តនោះបានកន្លងផុតទៅអស់រយៈពេល ៨ឆ្នាំទើបគាត់ប្តឹង។ ចំពោះអង្គហេតុឆ្នាំ២០១៥ អត់ឃើញមានការបញ្ជាក់ឱ្យច្បាស់លាស់អំពីការស៊ើបអង្កេតនោះទេ ព្រោះឆ្នាំ២០១៣ ជនជាប់ចោទបានឆ្លើយថា គាត់ទៅប៉ៃលិន។ សុំក្រុមប្រឹក្សាពិនិត្យពិចារណា និងសម្រេចទៅតាមច្បាប់ ព្រោះពេលប្រព្រឹត្តនោះជនជាប់ចោទគឺ ជាអនីតិជន។

-មេធាវី [redacted] ទេសកញ្ញៈនា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ដីវ៉ា ធ្វើសេចក្តីសន្និដ្ឋានដូចតទៅ នៅក្នុងរឿងនេះផងដែរ ដូចដែលចម្លើយរបស់ជនជាប់ចោទបានឆ្លើយសារភាព គោលបំណងប្តឹងឧទ្ធរណ៍មកនេះគឺ គាត់អត់បានប្រព្រឹត្តដូចតាមការចោទប្រកាន់ទេ។ ខ្លួនសូមគាំទ្រ និងយល់ស្របនូវសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការដែលបានលើកឡើង។ បើមើលទៅលើអត្ថន័យបទរំលោភសេពសន្ថវៈ គឺកូនក្តីខ្លួនមិនបានប្រព្រឹត្តដូចបទចោទប្រកាន់តាមមាត្រា២៣៩ នោះទេ គឺគាត់គ្រាន់តែបានយកប្រដាប់ភេទគាត់ទៅដាក់នៅពីលើប្រដាប់ភេទកុមារីរងគ្រោះ។ ដូចនេះសកម្មភាពនេះមិនមែនជាបទរំលោភសេពសន្ថវៈទេ វាជាករណីបទ ប្រទូសកេរខ្មាសទៅវិញ ដែលបទល្មើសនេះមានចែងនៅក្នុង

មាត្រា២៤៦ នៃក្រមព្រហ្មទណ្ឌ។ មួយវិញទៀតបើយើងមើលទៅលើអំឡុងពេលនៃការប្រព្រឹត្តបទល្មើសគឺនៅឆ្នាំ២០១២ ហើយបើមើលទៅលើលិខិតកោសល្យវិច័យគឺ ធ្វើនៅក្នុងឆ្នាំ២០២០ ដែលមានគម្លាតដល់ទៅ ៨ឆ្នាំ មានការមិនទាន់ច្បាស់លាស់។ ជាសំណូមពរ ចុងក្រោយដោយសារតែកូនក្តីរបស់ខ្លួនគាត់បានដឹងនូវទោសកំហុសរបស់គាត់ហើយ ហើយអំឡុងពេលនៃការប្រព្រឹត្តគឺ គាត់នៅជាអនីតិជន អាយុ ១៥ទៅ ១៦ឆ្នាំ ដូចនេះខ្លួនស្នើសុំក្រុមប្រឹក្សាមេត្តាពិចារណាប្តូរបទចោទប្រកាន់កូនក្តីខ្លួន ពីបទរំលោភសេពសន្ថវៈទាក់ទងនឹងជនរងគ្រោះ ទៅជាបទប្រទូសកេរខ្មាសតាមមាត្រា២៤៦ នៃក្រមព្រហ្មទណ្ឌ និងស្នើសុំបន្ធូរបន្ថយទោសយោងតាមមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។

-ក្រោយពីបាន ស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបាន ស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបាន ពិនិត្យគ្រប់ឯកសារ និងភស្តុតាងផ្សេងៗ

-ក្រោយពីបាន ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ

## យល់ឃើញថា

១-ពាក្យបណ្តឹងឧទ្ធរណ៍លេខ១០៩៦ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ធីរ៉ា ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ៩៣៥ "ក្រ₂ឈ" ចុះថ្ងៃទី២៣ ខែ វិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល បណ្តឹងធ្វើឡើងក្នុងកំណត់ច្បាប់យោងតាមបញ្ញត្តិមាត្រា៤៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងតាមបញ្ញត្តិ៣៧៥ មាត្រា៣៨២ ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌសាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន។

២-នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] ធីរ៉ា បានឆ្លើយថា៖ មូលហេតុប្តឹងឧទ្ធរណ៍ដោយសារក្នុងអង្គហេតុនៃរឿងមានពិតខ្លះ និងមិនពិតខ្លះ។ កាលកើតហេតុនោះគឺ នៅឆ្នាំ២០១២ បច្ចុប្បន្ននេះខ្លួនអាយុ ២៦ឆ្នាំ។ ជនរងគ្រោះត្រូវជាបងប្អូនជីដូនមួយខ្លួន កាលកើតហេតុនោះ ខ្លួនមិនសូវចាំទេ ជនរងគ្រោះអាយុប្រហែលជា ៨ឆ្នាំ។ ខ្លួនបានប្រព្រឹត្ត ៤ដងទៅលើជនរងគ្រោះ។ ពេលខ្លួនប្រព្រឹត្តនោះខ្លួនអាយុប្រហែលជា១៥ ទៅ ១៦ឆ្នាំ។ ឆ្នាំ២០១៣ ខ្លួនទៅនៅប៉ៃលិន ហើយឆ្នាំ២០១៥ ខ្លួនអត់បានប្រព្រឹត្តទេ ខ្លួនបានប្រព្រឹត្តតែអំឡុងឆ្នាំ២០១១ និង២០១២ទេ។ ខ្លួនទៅធ្វើការនៅទីនោះ។ ពេលនៅតុលាការសាលាដំបូងគេបន្ថែមអង្គហេតុឆ្នាំ២០១៥ចូលទៀត។ យាយខ្លួនគាត់ប្តូរពីផ្ទះនៅខេត្តព្រៃវែង មករស់នៅបឹងព្រលិតនៅចុងឆ្នាំ២០១១។ ពេលប្រព្រឹត្តនោះខ្លួននៅជាមួយបងប្អូនជីដូនមួយទាំងអស់ ៣នាក់ ហើយប្អូនគាត់ម្នាក់បានចេញទៅក្រៅ ខ្លួនក៏បានយកភួយទៅគ្របលើគាត់ ហើយខ្លួនបានរំលោភគាត់ពិតមែន តែអត់បានបង្ខិតបង្ខំគាត់ទេ។ ពេលនោះខ្លួននៅក្មេង ខ្លួនក៏បបួលគាត់ ខ្លួនបានថើបគាត់ បានដោះខោអាវគាត់ចេញអស់ហើយបានដាក់ប្រដាប់ភេទខ្លួននៅពីលើគាត់ អត់មានដាក់ចូលទេ។ អារម្មណ៍ពេលនោះខ្លួនចាំខ្លះអត់ខ្លះ។ ខ្លួនដឹងថា ខ្លួនធ្វើខុស។ ពេលប្រព្រឹត្តបទល្មើសនោះគឺ ពេលថ្ងៃ។ ពេលនោះអត់បានមើលវីដេអូអីទេ។ ខ្លួនអត់ដែរឃើញរូបភាពបែបនោះទេ។ អំឡុងពេលប្រព្រឹត្ត ១នាទីទៅ ១នាទីកន្លះ។ នៅក្នុងអំឡុងឆ្នាំ២០១២នោះខ្លួនប្រព្រឹត្ត ១ទៅ ២ដង ក្រោយប្រព្រឹត្តខ្លួនមានការស្តាយក្រោយ។ ខ្លួនឈប់ប្រព្រឹត្តហើយ។ ពីមុនមកខ្លួនអត់បានស្រលាញ់គ្នាមានស្នេហាអ្វីទេ។ ខ្លួនបាននិយាយជាមួយគាត់រឿងរួមភេទ តែអត់បានបង្ខិតបង្ខំ



Scanned with CamScanner

ជនរងគ្រោះទេ។ សំណូមពរ ខ្លួនសុំបន្ធូរបន្ថយទោស។ ក្រុមប្រឹក្សាយល់ឃើញថា ចម្លើយសារភាពអំពើប្រព្រឹត្តរបស់ជនជាប់ចោទមានភាពស៊ីសង្វាក់ទៅនឹងអង្គហេតុ និងចម្លើយរបស់ជនរងគ្រោះដែលអាចឱ្យក្រុមប្រឹក្សាជឿបានថា ជនជាប់ចោទពិតជាធ្វើសកម្មភាពរំលោភលើជនរងគ្រោះបានសម្រេចពិតប្រាកដមែន។ ដូច្នេះការឆ្លើយរបស់ជនជាប់ចោទឆ្លើយបដិសេធពុំបានប្រព្រឹត្តនៅក្នុងអំឡុងឆ្នាំ២០១៥ ត្រង់ចំណុចនេះជនជាប់ចោទ ពុំមានសាក្សី ឬភស្តុតាងណាមួយ ដើម្បីឱ្យក្រុមប្រឹក្សាជឿបានឡើយ។ មួយវិញទៀតទោះបីជាជនជាប់ចោទព្យាយាមលើកឡើងពីលក្ខខណ្ឌអាយុ និងកម្រិតនៃការយល់ដឹងយ៉ាងណាក្តី នោះមិនមែនជាលក្ខខណ្ឌនៃការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ពុំគប្បីក្រុមប្រឹក្សាលើកមកពិចារណា។

៣-តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញធ្វើសេចក្តីសន្និដ្ឋានថា៖ ពាក់ព័ន្ធនៅក្នុងរឿងនេះ ជនជាប់ចោទគាត់បានសារភាពថា បានប្រព្រឹត្តអំពើរួមភេទ ក៏ប៉ុន្តែគាត់អត់បានដាក់ប្រដាប់ភេទបញ្ចូលទៅ ក្នុងប្រដាប់ភេទជនរងគ្រោះទេ។ តាមលទ្ធផលកោសល្យវិច័យគឺ អត់មានដាច់សន្ធះព្រហ្មចារីយទេ។ ប៉ុន្តែមានភាពឆកនៅលើនោះ ដូចនេះបើជាការដាច់គឺ ពិតជាបានប្រព្រឹត្តសម្រេច។ ហើយចម្លើយរបស់ជនជាប់ចោទបានឆ្លើយថា គ្រាន់តែដាក់នៅពីលើទេ នេះជាចំណុចមួយសូមក្រុមប្រឹក្សាពិនិត្យ និងពិចារណា។ ហើយអំឡុងពេលដែលគាត់ប្រព្រឹត្តនោះគឺគាត់នៅក្មេងគាត់មិនទាន់មានការយល់ដឹងចំពោះរឿងនឹងឡើយ។ សូមក្រុមប្រឹក្សាពិនិត្យឡើងវិញទាក់ទងនឹងបទចោទប្រកាន់ ជាពិសេសចំពោះភស្តុតាងដាក់បន្ទុកគាត់ សុំប្តូរមកជាបទប្រទូសកេរខ្មាសវិញ ជាពិសេសពាក់ព័ន្ធនឹងអង្គហេតុ គឺកើតឡើងឆ្នាំ២០១២ ហើយការដាក់បណ្តឹងប្តឹងនៅឆ្នាំ២០២០។ បើចំពោះអង្គហេតុប្រទូសកេរខ្មាសវិញគឺ ជាបទមជ្ឈិម ការប្រព្រឹត្តនោះបានកន្លងផុតទៅអស់រយៈពេល ៨ឆ្នាំទើបគាត់ប្តឹង។ ចំពោះអង្គហេតុឆ្នាំ២០១៥ អត់ឃើញមានការបញ្ជាក់ឱ្យច្បាស់លាស់អំពីការស៊ើបអង្កេតនោះទេ ព្រោះឆ្នាំ២០១៣ ជនជាប់ចោទបានឆ្លើយថា គាត់ទៅប៉ៃលិន។ សុំក្រុមប្រឹក្សាពិនិត្យពិចារណា និងសម្រេចទៅតាមច្បាប់ ព្រោះពេលប្រព្រឹត្តនោះជនជាប់ចោទគឺជាអនីតិជន។ ចំពោះចម្លើយរបស់ជនជាប់ចោទដែលបានឆ្លើយថា អត់បានដាក់ប្រដាប់ភេទបញ្ចូលទៅក្នុងប្រដាប់ភេទជនរងគ្រោះទេ ត្រង់ចំណុចនេះក្រុមប្រឹក្សាយល់ឃើញថា គ្រាន់ជាលេសដោះសារដើម្បីឱ្យរួចផុតពីការចោទប្រកាន់តែប៉ុណ្ណោះ មិនអាចឱ្យក្រុមប្រឹក្សាជឿបានឡើយ ដោយហេតុថា តាមចម្លើយរបស់ជនរងគ្រោះបានឆ្លើយថា ដោយពេលនោះគាត់បានយកប្រដាប់ភេទរបស់គាត់ដាក់ចូលក្នុងប្រដាប់ភេទរបស់ខ្លួន តែមិនដឹងថា រយៈពេលប៉ុន្មាននាទីនោះទេ ពេលនោះក៏មានការឈឺចាប់ និងមានឈាមនៅប្រដាប់ភេទតែមិនហ៊ានប្រាប់យាយទេ ព្រោះឈ្មោះ ឆន ជីវ៉ា គាត់គំរាម។ បើយោងតាមលិខិតផលកោល វិច័យលេខ ២៣/២១ ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០២១ ដែលបានសន្និដ្ឋានថា សភាពរាងកាយទូទៅ ធម្មតា និងសភាពប្រដាប់ភេទផ្នែកខាងក្រៅមិនធម្មតា។ ចំពោះលក្ខខណ្ឌអាយុ និងការយល់ដឹងរបស់ជនជាប់ចោទគិតមកដល់ថ្ងៃប្រព្រឹត្តបទល្មើស ក្រុមប្រឹក្សាពិនិត្យឃើញថា ជនជាប់ចោទមានអាយុ ១៧ឆ្នាំហើយ ដូច្នេះកម្រិតនៃការយល់ដឹងរបស់ជនជាប់ចោទអាចពិចារណាបានហើយថា អំពើនេះជាអំពើខុសច្បាប់ ហើយស្ថិតក្នុងលក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌទៀតផង ដូច្នេះពុំអាចឱ្យក្រុមប្រឹក្សាពិចារណាឡើយ។ ចំណែកឯការស្នើសុំកែប្រែបទចោទមកជាបទល្មើសប្រទូសកេរខ្មាស ក្រុមប្រឹក្សាយល់ឃើញថា ពុំមានលក្ខណៈត្រឹមត្រូវឡើយ ដោយផ្អែកតាមចម្លើយរបស់ជនជាប់ចោទ ចម្លើយរបស់ជនរងគ្រោះ និងលទ្ធផលកោសល្យវិច័យរបស់ក្រុមគ្រូពេទ្យជំនាញ ឃើញថា នេះជាអង្គហេតុរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ(អនីតិជនអាយុ ៧ឆ្នាំ)។ ពាក់ព័ន្ធនឹងអង្គហេតុឆ្នាំ២០១២ ហើយការដាក់បណ្តឹងប្តឹងនៅឆ្នាំ



Scanned with CamScanner

២០២០ ត្រង់ចំណុចនេះក្រុមប្រឹក្សាពិនិត្យឃើញថា តាមចម្លើយរបស់ជនរងគ្រោះគឺ ជនជាប់ចោទបាន គំរាមសម្លាប់ ហើយជនរងគ្រោះរស់នៅជាមួយយាយតា និងរស់នៅក្នុងផ្ទះតែមួយជាមួយជនជាប់ចោទ ទៀតផង បើតាមការបញ្ជាក់ពីដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វណ្ណៈ ត្រូវជាម្តាយរបស់ជនរងគ្រោះថា ខ្លួនផ្ញើកូនជាមួយយាយក្នុងឆ្នាំ២០១២ និងយកកូនមកនៅជាមួយខ្លួនវិញក្នុងឆ្នាំ២០១៣ ខ្លួនបោកខោក្នុងឲ្យកូនស្រីឈ្មោះ [redacted] ម៉ូលីកា ឃើញខោក្នុងរបស់កូនប្លែកទើបសួរនាំគាត់ និងបានយកគាត់ទៅពិនិត្យនៅពេទ្យ។ ខ្លួនទើបដឹងក្នុងឆ្នាំ២០២០ នេះទេ មូលហេតុដែលខ្លួនទើបដឹងដោយសារពីមុនខ្លួនមិនបានបោកខោអាវកូនទេ ទើបតែបោកខោអាវឲ្យកូនឃើញខោក្នុងរបស់កូនមានក្លិនស្អុយ និងធ្លាក់ស។ នេះបញ្ជាក់បានថា ដោយសារតែមានការគំរាមកំហែងពីជនជាប់ចោទ និងការសាកសួរពីដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវជាម្តាយទើបដឹងថា ជនជាប់ចោទបានរំលោភលើជនរងគ្រោះ ហើយអាជ្ញាយុកាលនៃបទល្មើសនៅតែមានអានុភាពនៅឡើយ។

៤-មេធាវី [redacted] ទេសកញ្ញៈនា ការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖ នៅក្នុងរឿងនេះផងដែរ ដូចដែលចម្លើយរបស់ជនជាប់ចោទបានឆ្លើយសារភាព គោលបំណងប្តឹងឧទ្ធរណ៍មកនេះគឺគាត់អត់បានប្រព្រឹត្តដូចតាមការចោទប្រកាន់ទេ។ ខ្លួនសូមគាំទ្រ និងយល់ស្របនូវសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការដែលបានលើកឡើង។ បើមើលទៅលើអត្ថន័យបទរំលោភសេពសន្ថវៈ គឺកូនក្តីខ្លួនមិនបានប្រព្រឹត្តដូចបទចោទប្រកាន់តាមមាត្រា២៣៩ នោះទេ គឺគាត់គ្រាន់តែបានយកប្រដាប់ភេទគាត់ទៅដាក់នៅពីលើប្រដាប់ភេទកុមារីរងគ្រោះ។ ដូចនេះសកម្មភាពនេះមិនមែនជាបទរំលោភសេពសន្ថវៈទេ វាជាករណីបទប្រទូសកេរខ្មាសទៅវិញ ដែលបទល្មើសនេះមានចែងនៅក្នុងមាត្រា២៤៦ នៃក្រមព្រហ្មទណ្ឌ។ មួយវិញទៀតបើយើងមើលទៅលើអំឡុងពេលនៃការប្រព្រឹត្តបទល្មើសគឺ នៅឆ្នាំ២០១២ ហើយបើមើលទៅលើលិខិតកោសល្យវិច័យគឺ ធ្វើនៅក្នុងឆ្នាំ២០២០ ដែលមានគម្លាតដល់ទៅ៨ឆ្នាំ មានការមិនទាន់ច្បាស់លាស់។ ជាសំណូមពរចុងក្រោយ ដោយសារតែកូនក្តីរបស់ខ្លួនគាត់បានដឹងនូវទោសកំហុសរបស់គាត់ហើយ ហើយអំឡុងពេលនៃការប្រព្រឹត្តគឺ គាត់នៅជាអនីតិជនអាយុ១៥ ទៅ១៦ឆ្នាំ ដូចនេះនាងខ្លួន ស្នើសុំក្រុមប្រឹក្សាមេត្តា ពិចារណាប្តូរបទចោទប្រកាន់កូនក្តីនាងខ្លួន ពីបទរំលោភសេពសន្ថវៈទាក់ទងនឹងជនរងគ្រោះទៅជាបទប្រទូសកេរខ្មាស តាមមាត្រា២៤៦ នៃក្រមព្រហ្មទណ្ឌ និងស្នើសុំបន្ធូរបន្ថយទោសយោងតាមមាត្រា១៦០នៃក្រមព្រហ្មទណ្ឌ។ ចំពោះការស្នើសុំកែប្រែបទចោទប្រកាន់ និងលក្ខខណ្ឌអាយុរបស់ជនជាប់ចោទ ក្រុមប្រឹក្សាយល់ឃើញថា ពុំមានលក្ខណៈត្រឹមត្រូវឡើយ ដោយហេតុថា តាមចម្លើយសារភាពរបស់ជនជាប់ចោទ និងចម្លើយរបស់ជនរងគ្រោះមានភាពស៊ីសង្វាក់គ្នា ហើយអង្គហេតុខាងលើជាបទល្មើសរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ។

៥-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ធីរ៉ា ពីបទ រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ប្រព្រឹត្តនៅភូមិថ្មីក្រៅ ឃុំរះជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង កាលពីអំឡុងខែឧសភា ឆ្នាំ២០១២ និងនៅចំណុចភូមិបឹងព្រលិត សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ។

៦-សាលក្រមព្រហ្មទណ្ឌលេខ៩៣៥ "ក្រ₂ឈ" ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ធីរ៉ា ដាក់ពន្ធនាគារកំណត់ចំនួន ០៧(ប្រាំពីរ)ឆ្នាំ និងសំណងជម្ងឺចិត្តចំនួន ២០.០០០.០០០(ម្ភៃលាន)រៀល។ ក្រុមប្រឹក្សាយល់ឃើញថា ការសម្រេចសេចក្តីរបស់សាលាដំបូង មានលក្ខណៈត្រឹមត្រូវសមស្របទៅនឹង អំពើដែលជនជាប់ចោទបាន



Scanned with CamScanner

ប្រព្រឹត្ត និងទំហំនៃព្យសនកម្មដែលជនរងគ្រោះបានទទួលរង ហើយការផ្តន្ទាទោសនេះផងដែរក៏ស្ថិតនៅក្នុងកម្រិតអប្បបរមារួចហើយដែរ ដូច្នេះគប្បីក្រុមប្រឹក្សាសម្រេចតម្កល់សាលាក្រមព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ១០៩៦ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ របស់ឈ្មោះ [redacted] ដីវ៉ា ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយទាល់នឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៩៣៥ "ក្រ២ណ" ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តរាជធានីភ្នំពេញ ទុកជាបានការ។

៣-បន្តឃុំខ្លួនលើឈ្មោះ [redacted] ដីវ៉ា ដែលមានសវតាជាតិដូចខាងលើតាមនីតិវិធី។

សាលដីកានេះជំនុំជម្រះជាអសាធារណៈ នៅសាលសវនាការនៃសាលាឧទ្ធរណ៍នាថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ ចំពោះមុខឈ្មោះ [redacted] ដីវ៉ា និងប្រកាសជាអសាធារណៈនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២។

ទុកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ១១កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ,ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២

| បានឃើញ | ក្រឡាបញ្ជី |
|---|---|
| ប្រធានក្រុមប្រឹក្សា | |
| [redacted] | [redacted] |



Scanned with CamScanner